**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សុន្ទរកថាស្វាគមន៍របស់**
**ឧកញ៉ា បណ្ឌិត ប៊ុន មុនី ប្រធានក្រុមប្រឹក្សាភិបាលសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា**
**ខេត្តព្រះសីហនុ ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០១៥**

សូមគោរព៖

- លោកជំទាវ **អ៊ុក ម៉ាលី** អគ្គទេសាភិបាលរង ធនាគារជាតិនៃកម្ពុជា
- ឯកឧត្តម **ជូ វណ្ណៈ** អគ្គនាយករងនៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ឯកឧត្តម **យា ប៊ុណ្ណា** តំណាងឯកឧត្តម ស៊ុន គន្ធរ រដ្ឋមន្ត្រីអមនាយករដ្ឋមន្ត្រី
- លោក **រ័ត្ន សុវណ្ណនរៈ** អគ្គនាយករងនៃអគ្គនាយកដ្ឋានត្រួតពិនិត្យនៃ ធនាគារជាតិនៃកម្ពុជា
- ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី អ្នកនាង កញ្ញា ជាគោរព និងជាទីមេត្រី!!!

ថ្ងៃនេះសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជាយើងខ្ញុំមានសេចក្តីសោមនស្សរីករាយក្រៃលែងដែលបានរៀបចំធ្វើកម្មវិធីសន្និសីទមីក្រូហិរញ្ញវត្ថុប្រចាំឆ្នាំនេះឡើង ជាមួយគ្នានេះយើងខ្ញុំមានកិត្តិយស សូមសំដែងការគោរព និងស្វាគមន៍យ៉ាងកក់ក្តៅចំពោះវត្តមានឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី ជាគណៈអធិបតី និងអស់លោក លោកស្រីនិងអ្នកនាងកញ្ញា ភ្ញៀវកិត្តិយសជាតិ អន្តរជាតិ ដែលបានចូលរួមក្នុងអង្គសន្និសីទប្រចាំឆ្នាំ២០១៥ សម្រាប់វិស័យមីក្រូហិរញ្ញវត្ថុនាពេលនេះ។ ជាការពិតវិស័យមីក្រូហិរញ្ញវត្ថុកម្ពុជាបានទទួលជោគជ័យយ៉ាងធំធេង ដោយមានការទទួលស្គាល់ជាសកលក្នុងកំរិតជាតិ និងអន្តរជាតិយ៉ាងទូលំទូលាយ ។ ខ្ញុំមានជំនឿជាក់ថា "ការរីកចំរើន និងភាពជោគជ័យរបស់អតិថិជន គឺជាជោគជ័យពិតប្រាកដរបស់ស្ថាប័នមីក្រូហិរញ្ញវត្ថុ" ដូចនេះគ្រប់សកម្មភាពរបស់យើង គឺត្រូវទុកអតិថិជនជាអាទិភាព ដោយធានាថាពួកគាត់ពេញចិត្តចំពោះសេវាកម្មរបស់យើង នឹងទទួលបានផលប្រយោជន៍ ដែលធ្វើឲ្យមានជីវភាពរស់នៅប្រសើរឡើង និងឈានទៅកាត់បន្ថយភាពក្រីក្រប្រកបដោយជោគជ័យ។

សមាគម រៀបចំប្រារព្ធសន្និសីទប្រចាំឆ្នាំនេះឡើង ដើម្បីផ្សព្វផ្សាយអំពីជោគជ័យ និងសំដែងការអបអរសាទរចំពោះលទ្ធផលការងារដែលសមាជិកសមាគមសម្រេចបាន និងបង្កបរិយាកាសរីករាយឱ្យប្រតិបត្តិករមីក្រូហិរញ្ញវត្ថុ តំណាងស្ថាប័នរាជរដ្ឋាភិបាល និងម្ចាស់ជំនួយនានាបានជួបប្រាស្រ័យទាក់ទងគ្នាជាបណ្តាញការងារ និងផ្លាស់ប្តូរយោបល់គ្នាកាន់តែជិតស្និទ្ធ ព្រមទាំងលើកឡើងនូវអនុសាសន៍ ដើម្បីត្រៀមខ្លួននឹងការប្រឈមនានា ក្នុងពេលខាងមុខទៀត។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា សិក្ខាសាលារយៈពេល ១ថ្ងៃពេញនេះ ដែលផ្តោតការយកចិត្តទុកដាក់ទៅលើប្រធានបទ "កំណើនប្រកបដោយសុខភាពល្អដើម្បីការអភិវឌ្ឍដោយនិរន្តរភាព" នឹងនាំមកនូវផ្លែផ្កាជាទីគាប់ចិត្តសំរាប់គ្រប់គ្នាដែលធានានិរន្តរភាពរបស់វិស័យមីក្រូហិរញ្ញវត្ថុ និងការរីកចំរើនរបស់អតិថិជនផងដែរ។

**សមិទ្ធិផលគិតត្រឹមខែ កញ្ញា ឆ្នាំ ២០១៥**

សមាគម មានសមាជិកចំនួន ៦៣ ដែលមានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន៤៥ ទទួលបានអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា គ្រឹះស្ថានហិរញ្ញវត្ថុដទៃទៀតជាក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុចំនួន៦ និង ប្រតិបត្តិករឥណទានជនបទចំនួន ១២ (កាលពីខែកញ្ញា ឆ្នាំ ២០១៤ មានសមាជិកសរុប ៤៤ ដែលមានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន ៣៨ ទទួលបានអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា និងប្រតិបត្តិករឥណទានជនបទចំនួន ៦។ បច្ចុប្បន្នគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានកំពុងប្រតិបត្តិការនៅទូទាំង ២៥ រាជធានី-ខេត្ត តាមរយៈ ១,៣៥៤ ការិយាល័យតំណាង មានផលប័ត្រឥណទានប្រមាណ ២,៧២១ លាន ដុល្លារអាមេរិកនិងអតិថិជនចំនួន ១.៩៣១.៣៨១ នាក់ បើប្រៀបធៀបកាលពីខែកញ្ញា ឆ្នាំ២០១៤ មាន ១,១៥០ ការិយាល័យតំណាង មានផលប័ត្រឥណទានត្រឹមតែ ១,៧៩៧.៤៦លានដុល្លារអាមេរិកនិងអតិថិជនចំនួន ១.៧២០.៩៧៨ នាក់ ដែលកើនឡើងចំនួន ១៨% ៥១% និង១២% រៀងគ្នាក្នុងរយៈពេល ១ឆ្នាំ និងមានហានិភ័យឥណទានសងយឺតច្រើនជាង ៣០ ថ្ងៃ មានចំនួន ០,៦៦%។ ដោយឡែកគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន៧ ដែលទទួលបានទទួលអាជ្ញាប័ណ្ណទទួលប្រាក់បញ្ញើពីសាធារណៈជន និងបានកេណ្ឌប្រមូលបានប្រាក់បញ្ញើសន្សំចំនួន១,២៤១លានដុល្លារអាមេរិក និងមានអតិថិជនដាក់ប្រាក់បញ្ញើសន្សំចំនួន ១,៣៥១,៤១០នាក់ បើប្រៀបធៀបកាលពីខែកញ្ញាឆ្នាំ ២០១៤ យើងមានសមតុល្យប្រាក់បញ្ញើសន្សំប្រមាណ ៨១១ លាន ដុល្លារអាមេរិក និងមានអតិថិជនដាក់ប្រាក់បញ្ញើសន្សំចំនួន ១,០៥៤.៤៣៥ នាក់ដែលមានកំនើនឡើងចំនួន 53% និង ២៨% រៀងគ្នាក្នុងរយៈពេល១ឆ្នាំនេះ។ ទាំងនេះសបញ្ជាក់ឲ្យឃើញថា អតិថិជនកាន់តែមានជំនឿទុកចិត្តដល់ប្រតិបត្តិការ និងសេវាកម្មរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុកម្ពុជាយើង ហើយកត្តានេះក៏អាចឆ្លុះបញ្ចាំងបានថា វិស័យមីក្រូហិរញ្ញវត្ថុបាននិងកំពុងទទួលយកចូលក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋបានយ៉ាងមានជោគជ័យ។

សមិទ្ធិផលទទួលបានជាបន្តបន្ទាប់ដូចមានរៀបរាប់ខាងលើនេះ ធ្វើឲ្យខ្ញុំមានសុទិដ្ឋិនិយមយ៉ាងមុតមាំ ចំពោះការរីកចំរើនលើវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជានាពេលអនាគត នឹងស្ថិតនៅក្នុងនិន្នាការមួយល្អប្រសើរថែមទៀត ដើម្បីជាមធ្យោបាយទ្រទ្រង់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិឲ្យមានកំនើនខ្ពស់ជាពុំខាន និងឈានទៅកាត់បន្ថយភាពក្រីក្របានយ៉ាងមានប្រសិទ្ធិភាព។

ថ្ងៃនេះយើងមកជួបជុំគ្នានៅទីនេះជាថ្មីម្តងទៀតដើម្បី ពង្រឹងក្របខ័ណ្ឌវិជ្ជាជីវៈរបស់ប្រតិបត្តិករបន្ថែមទៀតធានាបាននូវស្ថេរភាពនៅក្នុងការប្រតិបត្តិការរបស់ខ្លួន ដែលក្នុងនោះយើងនឹងលើកយកបទពិសោធន៍ក្នុងការគាំពារអតិថិជន ការអប់រំហិរញ្ញវត្ថុ ការគ្រប់គ្រងឥណទានខ្នាតតូច ខ្នាតមធ្យម និងសេវាកម្មហិរញ្ញវត្ថុផ្សេងទៀត ព្រមទាំងការជជែកដេញដោលគ្នាអំពីយុទ្ធសាស្រ្តក្នុងការគ្រប់គ្រងការរីកចំរើន របស់គ្រឹះស្ថាននិមួយៗក្នុងស្ថានភាពរីកចំរើនដូចបច្ចុប្បន្ននេះ និងការការពារហានិភ័យផ្សេងៗធានាបានស្ថេរភាពនៃការរីកចំរើនរបស់វិស័យនេះប្រកបដោយនិរន្តភាព។ការជជែកដេញដោលនេះនឹងមានការចូលរួមពីគ្រឹះស្ថានធំៗចំនួន ៥គ្រឹះស្ថាន រួមមានគ្រឹះស្ថាន ប្រាសាក់ អម្រឹត ហត្ថាកសិករ អេអឹមខេ និងវីសិនហ្វាន់ ។

**ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី អ្នកនាង កញ្ញា ជាទីមេត្រី!**

ជោគជ័យទាំងអស់ដែលយើងទទួលបានកន្លងមកនេះ ក៏ដោយសារមានការសហការយ៉ាងល្អពីគ្រប់ភាគីពាក់ព័ន្ធជាពីសេសគឺការគាំទ្ររបស់រាជរដ្ឋាភិបាលដែល ធានាបាននូវ សន្តិសុខ សុវត្ថិភាពនិងស្ថេរភាពសង្គម ដែលជាកត្តាសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងតាមរយៈក្រសួងពាក់ព័ន្ធនានា ជាពិសេសធនាគារជាតិ នៃកម្ពុជា ដោយបង្កើតច្បាប់សំរាប់គ្រប់គ្រង និងបទបញ្ញាផ្សេងៗយ៉ាងសមស្របសំរាប់វិស័យនេះទាំងមូល ។ អ្នកវិនិយោគម្ចាស់ឥណទាន បានផ្តល់ទុនហិរញ្ញប្បទាន និងជំនួយ គាំទ្របច្ចេកទេស។ ការពង្រឹងសមត្ថភាព វិជ្ជាជីវៈរបស់ប្រតិបត្តិករ ខណៈដែលប្រតិបត្តិករ និងអតិថិជនរបស់ពួកគេបាន ដើរតួនាទីសំខាន់បំផុតក្នុងការធ្វើឲ្យបច្ចេកវិជ្ជានេះទទួលបានជោគជ័យ។ យើងខ្ញុំសង្ឃឹមថាភាគីពាក់ព័ន្ធទាំងអស់នឹងបន្តការគាំទ្រ និងពង្រឹងសមត្ថភាពរបស់ខ្លួនថែមទៀតដើម្បីចូលរួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជាធានាបានការរីកចំរើនប្រកបដោយរលូន ។

តាងនាមឲ្យក្រុមប្រឹក្សាភិបាល និងសមាជិកសមាគមមីក្រូហិរញ្ញវត្ថុ ខ្ញុំសូមថ្លែងអំណរគុណជាពន្លឹកដល់ដៃគូសហប្រតិបត្តិការទាំងអស់ ដែលបានគាំទ្រវិស័យនេះ ជាពិសេសទីភ្នាក់ងារអភិវឌ្ឍបារាំង (AFD) ដែលបានផ្តល់ថវិកា និងជំនួយបច្ចេកទេសគាំទ្រចាប់តាំងពីឆ្នាំ២០១៣-១៦ និងអង្គការ □□□ □□□□□□□□□□ ដែលបានផ្តល់មូលនិធិក្នុងការរៀបចំកម្មវិធីរៀងរាល់ឆ្នាំ និង សូមអរគុណផងដែរដល់ **ការិយាល័យឥណទាន** □□□ ដែលបានចូលរួមឧបត្ថម្ភអង្គសន្និសីទប្រចាំឆ្នាំ២០១៥នេះ។

ជាថ្មីម្តងទៀតខ្ញុំសូមសម្តែងនូវការស្វាគមន៍យ៉ាងកក់ក្តៅក្រៃលែង ចំពោះវត្តមាន ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី និងភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិដែលបានចូលរួមក្នុង អង្គសន្និសីទនាថ្ងៃនេះ និងសូមគោរពជូនពរសុខភាពល្អ និងជោគជ័យគ្រប់ភារកិច្ច។ រីករាយថ្ងៃបុណ្យណូអែល និង ជូនពរឆ្នាំថ្មី ២០១៦ ។

**សូមអរគុណ**!!!